# អាជ្ញាធរអគ្គិសនីកម្ពុជា

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

# សេចក្តីសម្រេចកែសម្រួលលើកទី២

## លើឯកសារអាជ្ញាប័ណ្ណរបស់លោក ស្រី សុខុម

## ធ្វើសេវាកម្មអគ្គិសនីនៅទីប្រជុំជនផ្សារសំរោងយោង ឃុំត្រពាំងសាប

## ស្រុកបាទី ខេត្តតាកែវ សម្រាប់ពង្រីកតំបន់ចែកចាយអគ្គិសនី

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីសម្រេចកែសម្រួលលើកទី២
# លើឯកសារអាជ្ញាប័ណ្ណលេខ ០១៥ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ ជាមួយសេចក្ដីសម្រេចកែសម្រួលលើកទី១ លេខ ០៨០សរ.០៤.អអក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤
# សម្រាប់លោក ស្រី សុខុម

## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ០១៥ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២

-យោងសេចក្ដីសម្រេចកែសម្រួលលើកទី១ លើឯកសារអាជ្ញាប័ណ្ណរបស់លោក ស្រី សុខុម លេខ០៨០ សរ-០៤-អអក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤

-យោងពាក្យស្នើសុំពង្រីកតំបន់ចែកចាយអគ្គិសនីរបស់លោក ស្រី សុខុម ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៦

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៧ ដល់ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៧

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី១០២ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៧

## សម្រេច

### ប្រការ១

កែសម្រួលអាជ្ញាប័ណ្ណលេខ ០១៥ ឯអ ដែលបានផ្ដល់ឱ្យលោក **ស្រី សុខុម** ដោយអនុញ្ញាតឱ្យពង្រីកតំបន់តាមបណ្ដោយផ្លូវជាតិលេខ២ ចាប់ពីព្រំប្រទល់តំបន់ចែកចាយអគ្គិសនីមានស្រាប់ឆ្ពោះទៅភ្នំពេញចំងាយ ៥០០ម៉ែត្រ និងភូមិចំនួន៤ គឺភូមិត្រពាំងទឹម ភូមិពូនភ្នំ ភូមិតស៊ូ និងភូមិស្លាកប្រើយ៍ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ដើម្បីអនុញ្ញាតឱ្យលោក **ស្រី សុខុម** ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់បន្ថែម ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ។

**ប្រការ២**

ឧបសម្ព័ន្ធទី១ ចាស់នៃអាជ្ញាប័ណ្ណលេខ ០១៥ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។

**ប្រការ៣**

សេចក្តីសម្រេចនេះនិងឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០១៥ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០១៥ឯអ និង ខ្លឹមសារដែលបានកែសម្រួលរួចហើយ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្ញើរសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាម ទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០១៥ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០១៥ឯអ ដែលតម្កល់ទុកនេះមានការកែសម្រួលជាថ្មី ស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៧

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី១

## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## លើកទី១០២ នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៧

១- តំបន់អនុញ្ញាតឱ្យលោក **ស្រី សុខុម** ធ្វើសេវាកម្មចែកចាយនិងផ្គត់ផ្គង់អគ្គិសនី គឺ តំបន់ទីប្រជុំជនផ្សារសំរោងយ៉ោង ឃុំត្រពាំងសាប ស្រុកបាទី ខេត្ត តាកែវ (ដូចមានបង្ហាញក្នុងផែនទីភ្ជាប់) ។

២- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើ លោក **ស្រី សុខុម** មានបំណង ស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះលោក **ស្រី សុខុម** ត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេច ឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។

# ឧបសម្ព័ន្ធទី២
# មធ្យោបាយផលិតកម្មដែលមានស្រាប់
# ធ្វើការកែសម្រួលលជាថ្មី ក្នុងសម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា
# លើកទី៧៩ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៦

## មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ

### ក. រោងម៉ាស៊ីន

១- រោងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ ស្ថិតនៅភូមិសែរ៉ា ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

### ខ. លក្ខណៈទូទៅនៃម៉ាស៊ីន

១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០២ គ្រឿង ដែលមានអានុភាព តម្លើងសរុប 115 KVA គឺ :

- ម៉ាស៊ីនទី១ : អានុភាពតម្លើង 75 kVA
- ម៉ាស៊ីនទី២ : អានុភាពតម្លើង 40 kVA

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងម៉ាស៊ូតសែល ។

### គ. ការស្នើសុំផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម

១- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម ពេលនោះអ្នកកាន់ អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរ អគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសំរេចអនុញ្ញាតឱ្យផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម ឧបសម្ព័ន្ធទី២នេះត្រូវធ្វើការកែសម្រួល ដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យផ្លាស់ប្តូរឬបន្ថែមមធ្យោបាយផលិតកម្មនោះ ។